## ខ្ញុំដល់ពេលអស់រដូវហើយ តើខ្ញុំនៅតែត្រូវធ្វើតេស្តផែបស្មៀឬ?

ពិតមែនហើយ អ្នកនៅតែធ្វើតេស្ត ពីព្រោះគ្រោះថ្នាក់នៃការកើតមហារីកកស្បូនមានកាន់តែខ្លាំង នៅពេលអ្នកមានអាយុកាន់តែច្រើន។ ប្រសិនបើអ្នកធ្លាប់បានរួមភេទ ទោះបីជាមួយដៃគូតែមួយក៏ដោយ នេះគឺជាការសំខាន់ដែលអ្នកត្រូវធ្វើតេស្តផែបស្មៀឲ្យបានទៀងរាល់ពីរឆ្នាំម្តង ទោះបីជាអ្នកអស់រដូវក៏ដោយ។

## ខ្ញុំសំគាល់ឃើញមានធ្លាក់ឈាមមិនប្រក្រតី (មិនធម្មតា) ខ្លះៗ

ប្រសិនបើអ្នកមានធ្លាក់ឈាម ឬមានធ្លាក់រំអិលសៗមិនធម្មតាណាមួយចេញពីយោនី សូមទៅជួបវេជ្ជបណ្ឌិតរបស់អ្នកជាបន្ទាន់។

## ខ្ញុំមិនចាំថាពេលណាដែលខ្ញុំ បានធ្វើតេស្តផែបស្មៀចុងក្រោយ

វេជ្ជបណ្ឌិត ឬមន្ទីរមើលថែសុខភាពរបស់អ្នក ប្រហែលជាមានប្រព័ន្ធសំរាប់រំឭកប្រាប់អ្នកអំពីពេលវេលាដែលអ្នកត្រូវធ្វើតេស្តផែបស្មៀបន្ទាប់។ នៅតាមរដ្ឋ ឬដែនដីនីមួយៗ គេមានរបៀបកត់ចូលបញ្ជីនូវលទ្ធផលនៃតេស្តផែបស្មៀរបស់អ្នក។ គេនឹងផ្ញើលិខិតរំឭកទៅអ្នក ប្រសិនបើវាហួសថ្ងៃកំណត់សំរាប់ការធ្វើតេស្តផែបស្មៀបន្ទាប់របស់អ្នក ឬដើម្បីតាមដានព្យាបាលបន្ត។ ប្រសិនបើអ្នកមិនចង់ឲ្យគេកត់ព័ត៌មានចូលក្នុងបញ្ជី ឬឲ្យគេផ្ញើលិខិតរំលឹកប្រាប់អ្នកទេ សូមនិយាយប្រាប់វេជ្ជបណ្ឌិតរបស់អ្នក។

## តើខ្ញុំអាចធ្វើតេស្តផែបស្មៀរបស់ខ្ញុំនៅកន្លែងណា?

អ្នកអាចធ្វើការណាត់ជួបមួយជាមួយវេជ្ជបណ្ឌិតរបស់អ្នក គិលានុបដ្ឋាក ឬមន្ទីរគំរោងគ្រួសារនៅក្នុងតំបន់របស់អ្នក។ អ្នកអាចស្នើសុំវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកស្ត្រីឲ្យធ្វើផែបស្មៀអ្នកក៏បានដែរ។ ប្រសិនបើអ្នកចង់បានអ្នកបកប្រែភាសា សូមនិយាយប្រាប់អំពីការនេះនៅពេលអ្នករៀបចំការណាត់ជួប។ អ្នកក៏អាចនាំយកមិត្តភ័ក្រ ឬសមាជិកគ្រួសារណាម្នាក់មកជាមួយអ្នកក៏បានដែរ ប្រសិនបើអ្នកចង់។

## ខ្ញុំបានឮសួរអំពីថ្នាំចាក់ដែលអាចបង្ការរោគមហារីកកស្បូន

ពិតមែនហើយ មានថ្នាំចាក់មួយដែលអាចបង្ការមេរោគប្រភេទ HPV ដែលបណ្តាលឲ្យកើតករណីនៃរោគមហារីកកស្បូនភាគច្រើន។ ថ្នាំចាក់នេះបានទទួលការអនុញ្ញាតយល់ព្រមឲ្យមាន នៅក្នុងប្រទេសអូស្ត្រាលីសំរាប់ស្ត្រីទាំងឡាយដែលមានអាយុចន្លោះ៩ឆ្នាំ និង២៦ឆ្នាំ។

ថ្នាំចាក់ HPV មានផ្តល់ជូនដោយឥតគិតថ្លៃនៅក្រោមកម្មវិធីជាតិលើការចាក់ថ្នាំបង្ការរោគ។

ការចាក់ថ្នាំនេះគឺល្អប្រសើរសំរាប់ចាក់ឲ្យមនុស្សវ័យក្មេង មុនគេចាប់ផ្តើមរួមភេទ។ ថ្នាំចាក់នេះផ្តល់ឡើងដើម្បីការពាររោគមហារីកកស្បូន ក្នុងចំណោមស្ត្រីជំនាន់ក្រោយៗ។ ប្រសិនបើអ្នកមានអាយុចន្លោះ១២ឆ្នាំ និង២៦ឆ្នាំ ឬប្រសិនបើអ្នកមានកូនស្រីដែលមានអាយុចន្លោះ១២ឆ្នាំ និង២៦ឆ្នាំ សូមនិយាយប្រាប់វេជ្ជបណ្ឌិតរបស់អ្នកអំពីការចាប់ផ្តើមចាក់ថ្នាំនេះ។

ការធ្វើតេស្តផែបស្មៀបានទៀងទាត់នៅតែជាការចាំបាច់ដដែល ដ្បិតអីការចាក់ថ្នាំនឹងជួយបង្ការប្រភេទខ្លះនៃវ៉ាយរ៉ីស HPV ដែលបណ្តាលឲ្យកើតរោគមហារីកកស្បូន។

**ការធ្វើតេស្តផែបស្មៀបានទៀងទាត់ នៅតែជាការចាំបាច់ដដែល ដ្បិតអីការចាក់ថ្នាំ មិនជួយការពារគ្រប់ទាំងប្រភេទនៃវ៉ាយរ៉ុស HPV ដែលអាចបណ្តាលឲ្យកើតរោគមហារីកកស្បូនឡើយ។**

ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀតស្តីអំពី HPV និងការចាក់ថ្នាំដែលមាននៅក្រោមកម្មវិធីចាក់ថ្នាំបង្ការរោគអូស្ត្រាលី សូមមើលវ៉ិបសាយ **www.immunise.health.gov.au**

**វិធីការពារប្រសើរជាងគេដើម្បីទប់ទល់ការពារនឹងរោគមហារីកកស្បូន គឺត្រូវធ្វើតេស្តផែបស្មៀឲ្យបានទៀងរាល់ពីរឆ្នាំម្តង។**

ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀតស្តីអំពីការធ្វើតេស្តផែបស្មៀ ឬប្រសិនបើអ្នកមានបំណងចង់រក្សាព័ត៌មានរបស់អ្នកឲ្យបានទាន់ពេល ឬយកចេញនូវព័ត៌មានរបស់អ្នក ចេញពីបញ្ជីធ្វើតេស្តផែបស្មៀនៅក្នុងរដ្ឋ ឬដែនដីរបស់អ្នក សូមទូរស័ព្ទលេខ **13 15 56** (ដោយអស់ថ្លៃទូរស័ព្ទដូចក្នុងតំបន់)។

ប្រសិនបើអ្នកមានបញ្ហាក្នុងការនិយាយជាភាសាអង់គ្លេស សូមទូរស័ព្ទទៅកិច្ចបំរើបកប្រែភាសាអត្ថបទ និងភាសានិយាយដើម្បីសុំជំនួយលេខ **13 14 50**។ ថ្លៃប្រើទូរស័ព្ទនេះអស់តម្លៃដូចថ្លៃប្រើទូរស័ព្ទក្នុងតំបន់។

អ្នកក៏អាចបើកមើលវ៉ិបសាយរបស់យើងបានដែរ នៅត្រង់កន្លែង **www.cancerscreening.gov.au**

Cambodian



# តើអ្នកបានធ្វើតេស្តផែបស្មៀ (ការធ្វើតេស្តឆែកមើលកស្បូន) ចុងក្រោយនៅពេលណា?

គេអាចបង្ការរោគមហារីកកស្បូនភាគច្រើន ប្រសិនបើស្ត្រីម្នាក់ៗបានធ្វើតេស្តផែបស្មៀទៀងរាល់ពីរឆ្នាំម្តង

**National Cervical Screening Program**

A joint Australian, State and Territory Government Initiative

**កុំនិយាយដោះសាឡើយ ហើយសូមធ្វើការណាត់ជួបទៅ**

## តើផែបស្មៀជាអ្វី?

ផែបស្មៀគឺជាការធ្វើតេស្តដ៏មើលងាយស្រួលមួយ ដើម្បីឆែកមើលកស្បូនរបស់អ្នកឲ្យប្រាកដច្បាស់ថាវាមានសុខភាពល្អ។ កស្បូនរបស់អ្នកគឺជាមាត់ច្រកនៃស្បូន ហើយវាស្ថិតនៅផ្នែកខាងលើយោនីរបស់អ្នក (សូមមើលរូបភាពខាងក្រោមនេះ)។

ការធ្វើតេស្តផែបស្មៀត្រូវការពេលតែពីរ ឬបីនាទីប៉ុណ្ណោះ ហើយមិនធ្វើឲ្យឈឺចាប់អ្វីទេ។

ការធ្វើតេស្តផែបស្មៀរៀងរាល់ពីរឆ្នាំម្តង គឺជាវិធីប្រសើរបំផុតដើម្បីបង្ការនូវការកើតមាននៃរោគមហារីកកស្បូន។




## ហេតុអ្វីបានជាធ្វើតេស្តផែបស្មៀ?

តេស្តផែបស្មៀអាចបង្ហាញឲ្យឃើញនូវសញ្ញាឲ្យដឹងជាមុន ពីរោគមហារីកកស្បូន។ ជួនកាលកោសិកាតូចៗនៃកស្បូនចាប់ផ្តើមផ្លាស់ប្តូរពីសុខភាពល្អទៅសុខភាពមិនល្អ (ភាពមិនប្រក្រតី)។ តេស្តផែបស្មៀអាចរកឃើញនូវកោសិកាមិនប្រក្រតី មុននឹងវាក្លាយទៅជារោគមហារីក។

## តើអ្វីបណ្តាលឲ្យកើតរោគមហារីកកស្បូន?

មេរោគដែលមានវ៉ាយរ៉ុសមួយហៅថា HPV (human papillomavirus) ដែលបណ្តាលឲ្យកើតរោគមហារីកកស្បូនភាគច្រើន។ មានប្រភេទនៃវ៉ាយរ៉ុស HPV ច្រើនជាង១០០ខុសៗគ្នា។ មានប្រភេទពីរនៃប្រភេទវ៉ាយរ៉ុសទាំងនេះ ត្រូវបានគេស្គាល់ថា បណ្តាលឲ្យកើតករណីនៃរោគមហារីកកស្បូនភាគច្រើន នៅក្នុងប្រទេសអូស្ត្រាលី។

HPV កើតមានជាទូទៅណាស់។ ស្ត្រីភាគច្រើន (មាន៤នាក់ ក្នុងចំណោម៥នាក់) នឹងកើត HPV ក្នុងពេលមួយក្នុងជីវិតរស់នៅរបស់គេ។ នរណាម្នាក់ដែលធ្លាប់បានរួមភេទ នោះគេអាចកើត HPV។

នៅក្នុងករណីភាគច្រើន HPV អាចជាបាត់ដោយខ្លួនវាក្នុងរយៈពេលពីរ ឬបីឆ្នាំ។ ជួនកាលវ៉ាយរ៉ុសនេះអាចស្ថិតនៅក្នុងដងខ្លួនរបស់អ្នកយូរជាងនេះ ហើយអាចបណ្តាលឲ្យកើតរោគមហារីកកស្បូន។ ធម្មតាការនេះត្រូវប្រើពេលវែងជាងនេះ - ប្រហែលជា១០ឆ្នាំ។

ការធ្វើតេស្តផែបស្មៀរៀងរាល់ពីរឆ្នាំម្តង អាចរកឃើញកោសិកាផ្លាស់ប្តូរណាមួយដែលបណ្តាលឲ្យកើត HPV មុននឹងវាក្លាយទៅជារោគមហារីក។ វេជ្ជបណ្ឌិតរបស់អ្នក គិលានុបដ្ឋាក ឬបុគ្គលិកផ្នែកសុខភាពអាចជួយបានច្បាស់ប្រាកដថាសុខភាពរបស់អ្នកត្រូវបានគេពិនិត្យឃ្លាំមើល ហើយថាអ្នកបានទទួលការព្យាបាល ប្រសិនបើអ្នកត្រូវការ ដើម្បីឲ្យអ្នកនៅតែមានសុខភាពល្អដដែល។

## តើនរណាខ្លះត្រូវការធ្វើតេស្តផែបស្មៀ?

គ្រប់ស្ត្រីទាំងអស់ដែលមានអាយុក្នុងចន្លោះ១៨ឆ្នាំ ទៅ៧០ឆ្នាំដែលធ្លាប់បានរួមភេទ គួរធ្វើតេស្តផែបស្មៀឲ្យបានរៀងរាល់ពីរឆ្នាំម្តង។ ទោះបីជាអ្នកបានរួមភេទជាមួយតែប្តីរបស់អ្នកក្តី អ្នកគួរតែធ្វើតេស្តផែបស្មៀឲ្យបានទៀងទាត់។

## ចុះប្រសិនបើខ្ញុំបានកាត់ស្បូនចេញរួចហើយ

អ្នកប្រហែលជានៅតែធ្វើតេស្តផែបស្មៀដដែល ដោយយោងទៅលើប្រភេទនៃការកាត់យកស្បូនចេញដែលអ្នកបានធ្វើ។ សូមពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់អ្នក គិលានុបដ្ឋាក ឬបុគ្គលិកផ្នែកសុខភាពអំពីវិធីប្រសើរជាងគេណាមួយសំរាប់អ្នក។

## តើគេធ្វើតេស្តផែបស្មៀដោយរបៀបណា?






## គេធ្វើដូចតទៅនេះ....

ជាដំបូង វេជ្ជបណ្ឌិតប្រាប់អ្នកឲ្យដោះសំលៀកបំពាក់ចេញចាប់ពីចង្កេះចុះក្រោម ហើយឲ្យដេកផ្ងារ ដើម្បីឲ្យគេពិនិត្យមើល។ អ្នកអាចស្នើសុំឲ្យវេជ្ជបណ្ឌិតស្ត្រីធ្វើការពិនិត្យនេះបាន។ បន្ទាប់មក វេជ្ជបណ្ឌិតនឹងប្រើគ្រឿងប្រដាប់ពេទ្យម៉្យាងហៅថា ស្ពេឃ្យូឡូម (ឧបករណ៍ពេទ្យ) វែកយោនីរបស់អ្នក ដើម្បីឲ្យគេអាចមើល ឃើញកស្បូនរបស់អ្នកដោយងាយស្រួល។

គេប្រើកូនច្រាស ឬប្រដាប់សំរាប់វែកមើល (បន្ទះជ័រ ឬឈើតូច) មួយដើម្បីកៀរយ៉ាងស្រាលៗ យកកោសិកាខ្លះចេញពីកស្បូនរបស់អ្នក។ គេដាក់កោសិកាទាំងនេះនៅពីលើកូនបន្ទះកញ្ចក់មួយ ហើយផ្ញើទៅមន្ទីរពិសោធន៍ដែលនៅទីនោះគេពិនិត្យមើលកោសិកាទាំងនោះតាមអតិសុខុមទស្សន៍។

## តើវាអារម្មណ៍ដូចម្តេចដែរ?

ជួនកាលការធ្វើតេស្តផែបស្មៀអាចមានអារម្មណ៍ខ្មាស់អៀន។ ចូរចងចាំថា ចំពោះជនដែលបំពេញកិច្ចការផែបស្មៀនេះគ្រាន់តែជាផ្នែកកិច្ចការប្រចាំថ្ងៃរបស់គេប៉ុណ្ណោះ ហើយគេមិនខ្មាស់អៀនអ្វីឡើយ។

ទម្រង់ការនេះអាចមានអារម្មណ៍មិនស្រួលបន្តិច ក៏ប៉ុន្តែវាមិនគួរឲ្យឈឺចាប់ឡើយ។ ប្រសិនបើឈឺចាប់ សូមអ្នកនិយាយប្រាប់វេជ្ជបណ្ឌិតរបស់អ្នក គិលានុបដ្ឋាក ឬបុគ្គលិកផ្នែកសុខភាពឲ្យបានភ្លាមៗ។

## ចុះចំណែកលទ្ធផលនោះវាយ៉ាងណាដែរ?

នៅពេលអ្នកធ្វើតេស្តផែបស្មៀ នេះគឺជាការសំខាន់ដែលអ្នកត្រូវសួរវេជ្ជបណ្ឌិតរបស់អ្នកថាតើពេលណា និងធ្វើយ៉ាងណាដើម្បីឲ្យអ្នកបានដឹងអំពីលទ្ធផល។

**លទ្ធផលភាគច្រើន មានភាពធម្មតាទេ**

## ចុះប្រសិនបើលទ្ធផលរបស់ខ្ញុំមានភាពមិនប្រក្រតីវិញ?

ប្រសិនបើលទ្ធផលរបស់អ្នកមិនមានភាពប្រក្រតីទេ នេះមិនមែនមានន័យថាអ្នកមានរោគមហារីកឡើយ។ ជាញឹកញយណាស់ ប្រហែលជាមានន័យថាអ្នកមានអាការៈរោគសាមញ្ញអ្វីមួយដូចជាដំបៅ ដែលអាចនឹងជាស្រឡះដោយខ្លួនវា។

ជួនកាលស្ត្រីអាចត្រូវការធ្វើតេស្តផែបស្មៀឲ្យបានញឹកញាប់ជាងធម្មតា។ ប្រភេទនៃកោសិកាមិនប្រក្រតីខ្លះ អាចត្រូវការព្យាបាលដោយគ្រូពេទ្យឯកទេស។ សូមឲ្យបានប្រាកដថា អ្នកនិយាយទៅកាន់វេជ្ជបណ្ឌិតរបស់អ្នក គិលានុបដ្ឋាក ឬបុគ្គលិកផ្នែកសុខភាពអំពីវិធីណាមួយដែលប្រសើរជាងគេសំរាប់អ្នក។